# សេខិយ

ព្រមទាំងបទភាជនីយ៍

(សម្រាប់សូត្រ)

DHAMMA

DHAMMAPADHIPA FOR EDUCATION OF CAMBODIA

រៀបរៀងដោយ

ភិក្ខុវិមលោ **សាន ថាវីន**

**ព.ស.២៥៦៧**

# សេខិយ

ព្រមទាំងបទភាជនីយ៍ បាលី-ប្រែ

(សម្រាប់សូត្រ)

រៀបរៀងដោយ

ភិក្ខុវិមលោ **សាន ថាវីន**

**ព.ស.២៥៦៧**

# អារម្ភកថា

សៀវភៅតូចនេះធ្វើឡើងសម្រាប់សមណសិស្សងាយស្រួល ក្នុងការកាន់ទទ្វេញបានគ្រប់កន្លែង ព្រមទាំងងាយស្រួលក្នុងការ មើល ព្រោះទម្រង់អក្សរធម្មតា មិនស្មុគស្មាញពេក ។

ខ្ញុំសង្ឃឹមថាសៀវភៅនេះ នឹងក្លាយជាដៃគូរសមណសិស្ស ដើម្បីទន្ទេញ និងទ្រទ្រង់ចាំទុកនូវព្រះពុទ្ធវចនៈដែលជាមូលដ្ឋាន សម្រាប់ការប្រតិបត្តិដើម្បីចេញចាកអំពីវដ្តសង្សារ ។

សូមឧទ្ទិសនូវធម្មទាននេះ ដល់អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់ មានក្រុមជំនុំព្រះត្រៃបិដកជាដើម ព្រមទាំងញាតិកាទាំងឡាយ ក្នុងសង្សារវដ្តទាំងអស់ សូមបាននូវសេចក្តីសុខរួចផុតចាក ទុក្ខកុំបីអាក់ខានឡើយ ។

# សេខិយ

**ឥមេ ខោ បនាយស្មន្តោ ( បញ្ចសត្តតិ )[១] សេខិយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។** បពិត្រលោកអ្នកមានអាយុទាំងឡាយ វត្តដែលគប្បីសិក្សាទាំងឡាយ (ចិតសិបប្រាំ) នេះឯង មកកាន់ឧទ្ទេស (គឺការសម្តែងឡើង) ។

**១-បរិមណ្ឌលំ និវាសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងស្លៀក (ស្បង់) ឱ្យជាបរិមណ្ឌល ។

**បរិមណ្ឌលំ និវាសេតព្វំ នាភិមណ្ឌលំ ជានុមណ្ឌលំ បដិច្ឆាទេន្តេន** ភិក្ខុត្រូវស្លៀកឱ្យជាបរិមណ្ឌល គឺបិទបាំងមណ្ឌលផ្ចិត មណ្ឌលជង្គង់ ។

**យោ អនាទរិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ និវាសេតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយស្លៀកឱ្យស្លុយមុខ ឬស្លុយក្រោយ ត្រូវអាបត្តិទុក្កដ ។

---

[១] បាលីក្នុងវង់ក្រចកនេះបញ្ចូលថ្មី ដើម្បីប្រាប់ឱ្យដឹងចំនួនសេខិយសិក្ខាបទ ៧៥ ឯក្នុងវិន័យបិដកមិនមានបាលីនេះទេ ។

**២-បរិមណ្ឌលំ បារុបិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងដណ្ដប់ (គឺគ្រង) ចីវរឱ្យជាបរិមណ្ឌល ។

**បរិមណ្ឌលំ បារុបិតព្វំ ឧភោ កណ្ណេ សមំ កត្វា ។** ភិក្ខុគប្បីដណ្ដប់ឱ្យជាបរិមណ្ឌល គឺធ្វើនូវជាយទាំងពីរ ឱ្យត្រឹមស្មើគ្នា ។

**យោ អនាទរិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ បារុបតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ដណ្ដប់ (ចីវរ) ឱ្យស្រុយមុខខ្លះ ស្រុយក្រោយខ្លះ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

**៣-សុប្បដិច្ឆន្នោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងបិទបាំងកាយ (គឺឃ្លុំ) ឱ្យល្អដើរទៅក្នុងចន្លោះផ្ទះ ។

**សុប្បដិច្ឆន្នេន អន្តរឃរេ គន្តព្វំ ។** ភិក្ខុត្រូវបិទបាំងឱ្យល្អដើរទៅក្នុងចន្លោះផ្ទះ ។

**យោ អនាទរិយំ បដិច្ច កាយំ វិវរិត្វា អន្តរឃរេ គច្ឆតិ,**

**អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយបើកចំហកាយ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**៤-សុប្បដិច្ឆន្នោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងបិទបាំងកាយ (គឺឃ្លុំ) ឱ្យល្អអង្គុយក្នុងចន្លោះផ្ទះ ។

**សុប្បដិច្ឆន្នេន អន្តរឃរេ និសីទិតព្វំ ។** ភិក្ខុត្រូវបិទបាំងឱ្យល្អ អង្គុយនៅក្នុងចន្លោះផ្ទះ ។

**យោ អនាទរិយំ បដិច្ច កាយំ វិវរិត្វា អន្តរឃរេ និសីទតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយបើកចំហកាយ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**៥-សុសំវុតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងសង្រួម ឱ្យល្អដើរទៅក្នុងចន្លោះផ្ទះ ។

**សុសំវុតេន អន្តរឃរេ គន្តព្វំ ។** ភិក្ខុត្រូវតែសង្រួមឱ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ។

**យោ អនាទរិយំ បដិច្ច ហត្ថំ វា បាទំ វា កីឡាបេន្តោ**

**អន្តរឃរេ គច្ឆតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយគ្រវាត់គ្រវែងដៃខ្លះ ជើងខ្លះ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**៦-សុសំវុតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងសង្រួម ឱ្យល្អអង្គុយក្នុងចន្លោះផ្ទះ ។

**សុសំវុតេន អន្តរឃរេ និសីទិតព្វំ ។** ភិក្ខុត្រូវតែសង្រួមឱ្យល្អអង្គុយនៅក្នុងចន្លោះផ្ទះ ។

**យោ អនាទរិយំ បដិច្ច ហត្ថំ វា បាទំ វា កីឡាបេន្តោ អន្តរឃរេ និសីទតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយវាសដៃ ឬវាសជើង អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**៧-ឱក្ខិត្តចក្ខុ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមានភ្នែកសម្លឹងចុះ ដើរទៅក្នុងចន្លោះផ្ទះ ។

**ឱក្ខិត្តចក្ខុនា អន្តរឃរេ គន្តព្វំ យុគមត្តំ បេក្ខន្តេន ។** ភិក្ខុត្រូវតែមានភ្នែកសម្លឹងចុះ ដើរទៅក្នុងចន្លោះផ្ទះ ក្រឡេក

មើលត្រឹមតែមួយជួរនឹម[២] ។

**យោ អនាទរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ អន្តរ-ឃរេ គច្ឆតិ, អាបត្តិ ទុក្កដស្ស** ។ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយក្រឡេកមើលត្រង់ទីនោះ ៗ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**៨-ឱក្ខិត្តចក្ខុ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ។ ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមានភ្នែកសម្លឹងចុះអង្គុយក្នុងចន្លោះផ្ទះ ។

**ឱក្ខិត្តចក្ខុនា អន្តរឃរេ និសីទិតព្វំ យុគមត្តំ បេក្ខន្តេន** ។ ភិក្ខុត្រូវតែមានភ្នែកសម្លឹងចុះត្រឹមតែមួយជួរនឹម អង្គុយនៅក្នុងចន្លោះផ្ទះ ។

**យោ អនាទរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ អន្តរ-ឃរេ និសីទតិ, អាបត្តិ ទុក្កដស្ស** ។ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយក្រឡេកមើលត្រង់ទីនោះ ៗ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**៩-ន ឧក្ខិត្តកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា**

---

[២] មួយជួរនឹមស្មើនឹង ៤ ហត្ថរបស់ជាងឈើ (ប្រហែលជា ២ ម៉ែត្រ) ។

**ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសើយចីវរដើរទៅក្នុងចន្លោះផ្ទះ ។

**ន ឧក្ខិត្តកាយ អន្តរឃរេ គន្តព្វំ ។** ភិក្ខុមិនត្រូវសើយចីវរដើរទៅក្នុងចន្លោះផ្ទះទេ ។

**យោ អនាទរិយំ បដិច្ច ឯកតោ វា ឧភតោ វា ឧក្ខិបិត្វា អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយសើយចីវរខាងម្ខាង ឬទាំងពីរខាង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**១០-ន ឧក្ខិត្តកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសើយចីវរអង្គុយក្នុងចន្លោះផ្ទះ ។

**ន ឧក្ខិត្តកាយ អន្តរឃរេ និសីទិតព្វំ ។** ភិក្ខុមិនត្រូវសើយចីវរ អង្គុយនៅក្នុងចន្លោះផ្ទះទេ ។

**យោ អនាទរិយំ បដិច្ច ឯកតោ វា ឧភតោ វា ឧក្ខិបិត្វា អន្តរឃរេ និសីទតិ អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយសើយចីវរខាងម្ខាង ឬទាំងពីរខាង អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

## បរិមណ្ឌលវគ្គោ បឋមោ

បរិមណ្ឌលវគ្គទី១ (ចប់)

**១១-ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខាករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ។

**ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គន្តព្វំ ។** ភិក្ខុមិនត្រូវសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះទេ ។

**យោ អនាទរិយំ បដិច្ច មហាហសិតំ ហសន្តោ អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**១២-ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសើចខ្លាំងអង្គុយក្នុងចន្លោះផ្ទះ ។

**ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិតព្វំ ។** ភិក្ខុមិនត្រូវសើចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះទេ[៣] ។

**យោ អនាទរិយំ បដិច្ច មហាហសិតំ ហសន្តោ អន្តរ-**

---

[៣] ក្នុងបិដកថា " ឡើយ " ។

**ឃរេ និសីទតិ អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយសើចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះត្រូវអាបត្តិទុក្កដ ។

**១៣-អប្បសទ្ទោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងនិយាយសំឡេងតិចដើរទៅក្នុងចន្លោះផ្ទះ ។

**អប្បសទ្ទេន អន្តរឃរេ គន្តព្វំ ។** ភិក្ខុត្រូវមានសំឡេងតិចដើរទៅក្នុងចន្លោះផ្ទះ ។

**យោ អនាទរិយំ បដិច្ច ឧច្ចាសទ្ទំ មហាសទ្ទំ ករោន្តោ អន្តរឃរេ គច្ឆតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើនូវសំឡេងហ៊ោ សំឡេងឮខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**១៤-អប្បសទ្ទោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងនិយាយសំឡេងតិចអង្គុយក្នុងចន្លោះផ្ទះ។

**អប្បសទ្ទេន អន្តរឃរេ និសីទិតព្វំ ។** ភិក្ខុត្រូវតែមានសំឡេងតិច អង្គុយនៅក្នុងចន្លោះផ្ទះ ។

**យោ អនាទរិយំ បដិច្ច ឧច្ចាសទ្ទំ មហាសទ្ទំ ករោន្តោ អន្តរឃរេ និសីទតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយធ្វើនូវសំឡេងហៅ សំឡេងឮខ្លាំងអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**១៥-ន កាយប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនគ្រវែងកាយដើរទៅក្នុងចន្លោះផ្ទះ។

**ន កាយប្បចាលកំ អន្តរឃរេ គន្តព្វំ កាយំ បគ្គហេត្វា គន្តព្វំ ។** ភិក្ខុមិនត្រូវធ្វើកាយឱ្យគ្រវែងដើរទៅក្នុងចន្លោះផ្ទះទេ ត្រូវផ្គត់ផ្គង់កាយដើរទៅ (ក្នុងចន្លោះផ្ទះ) ។

**យោ អនាទរិយំ បដិច្ច កាយប្បចាលកំ អន្តរឃរេ គច្ឆតិ កាយំ ឱលម្ពេន្តោ អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយគ្រវែងកាយ យោលកាយដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**១៦-ន កាយប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនគ្រវែងកាយអង្គុយក្នុងចន្លោះផ្ទះ ។

**ន កាយប្បចាលកំ អន្តរឃរេ និសីទិតព្វំ ។** ភិក្ខុមិនត្រូវគ្រលែងកាយ អង្គុយនៅក្នុងចន្លោះផ្ទះទេ ត្រូវតែផ្គត់ផ្គង់កាយ ហើយអង្គុយនៅ (ក្នុងចន្លោះផ្ទះ) ។

**យោ អនាទរិយំ បដិច្ច កាយប្បចាលកំ អន្តរឃរេ និសីទតិ កាយំ ឱលម្ពេន្តោ អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយឃ្លោងកាយ យោលកាយ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**១៧-ន ពាហុប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនបង់បោយ ដើរទៅក្នុងចន្លោះផ្ទះ ។

**ន ពាហុប្បចាលកំ អន្តរឃរេ គន្តព្វំ ពាហុំ បគ្គហេត្វា គន្តព្វំ ។** ភិក្ខុមិនត្រូវបង់បោយដើរទៅក្នុងចន្លោះផ្ទះទេ ត្រូវដាក់ដៃឱ្យស្រួល ដើរទៅ (ក្នុងចន្លោះផ្ទះ) ។

**យោ អនាទរិយំ បដិច្ច ពាហុប្បចាលកំ អន្តរឃរេ គច្ឆតិ ពាហុំ ឱលម្ពេន្តោ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយបង់បោយវាសដៃ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**១៨-ន ពាហុប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា** ។ ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆ្ការរដៃអង្គុយក្នុងចន្លោះផ្ទះ ។

**ន ពាហុប្បចាលកំ អន្តរឃរេ គន្តព្វំ ពាហុំ បគ្គហេត្វា និសីទិតព្វំ** ។ ភិក្ខុមិនត្រូវឆ្ការរដៃ អង្គុយនៅក្នុងចន្លោះផ្ទះទេ ត្រូវដាក់ដៃឱ្យស្រួលអង្គុយនៅក្នុងចន្លោះផ្ទះ ។

**យោ អនាទរិយំ បដិច្ច ពាហុប្បចាលកំ អន្តរឃរេ និសីទតិ ពាហុំ ឱលម្ពេន្តោ, អាបត្តិ ទុក្កដស្ស** ។ ភិក្ខុណា អាស្រ័យ សេចក្តីមិនអើពើ ហើយឆ្កាដៃ វាសដៃ អង្គុយ នៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**១៩-ន សីសប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា** ។ ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនអង្រួនក្បាល ដើរទៅក្នុងចន្លោះផ្ទះ។

**ន សីសប្បចាលកំ អន្តរឃរេ គន្តព្វំ សីសំ បគ្គហេត្វា គន្តព្វំ** ។ ភិក្ខុមិនត្រូវ គ្រវែងក្បាល ដើរទៅក្នុងចន្លោះផ្ទះទេ ត្រូវតែផ្គង់តម្រង់ ក្បាលឱ្យស្រួលដើរទៅ ។

**យោ អនាទរិយំ បដិច្ច សីសប្បចាលកំ អន្តរឃរេ**

**គច្ឆតិ សីសំ ឱលម្ពេន្តោ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ គ្រលែងក្បាល រេក្បាល ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**២០-ន សីសប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនអង្រួនក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ។

**ន សីសប្បចាលកំ អន្តរឃរេ និសីទិតព្វំ សីសំ បគ្គហេត្វា និសីទិតព្វំ ។** ភិក្ខុមិនត្រូវ គ្រលែងក្បាល អង្គុយនៅក្នុងចន្លោះផ្ទះទេ ត្រូវតែផ្គងតម្រង់ក្បាលឱ្យស្រួល អង្គុយនៅ ។

**យោ អនាទរិយំ បដិច្ច សីសប្បចាលកំ អន្តរឃរេ និសីទតិ សីសំ ឱលម្ពេន្តោ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ ហើយគ្រលែងក្បាល រេក្បាល អង្គុយនៅ ក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**ឧជ្ជគ្ឃិកវគ្គោ ទុតិយោ**

ឧជ្ជគ្ឃិកវគ្គទី២ (ចប់)

**២១-ន ខម្ភកតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា**

**ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សា ថា អាត្មាអញនឹង មិនយកដៃស៊ីមចង្កេះដើរទៅក្នុងចន្លោះផ្ទះ ។

**ន ខម្ភកតេន អន្តរឃរេ គន្តព្វំ ។** ភិក្ខុមិនត្រូវស៊ីមចង្កេះដើរទៅក្នុងចន្លោះផ្ទះទេ ។

**យោ អនាទរិយំ បដិច្ច ឯកតោ វា ឧភតោ វា ខម្ភំ កត្វា អន្តរឃរេ គច្ឆតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយធ្វើនូវកិរិយាស៊ីមចង្កេះ តែម្ខាងក្ដី ទាំងពីរខាងក្ដី ហើយដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**២២-ន ខម្ភកតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនយកដៃស៊ីមចង្កេះអង្គុយក្នុងចន្លោះផ្ទះ ។

**ន ខម្ភកតេន អន្តរឃរេ និសីទិតព្វំ ។** ភិក្ខុមិនត្រូវ (យកដៃ) ស៊ីមចង្កេះ ហើយអង្គុយនៅក្នុងចន្លោះផ្ទះទេ ។

**យោ អនាទរិយំ បដិច្ច ឯកតោ វា ឧភតោ វា ខម្ភំ កត្វា អន្តរឃរេ និសីទតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយធ្វើនូវកិរិយាស៊ីមចង្កេះ តែម្ខាងក្ដី ទាំងពីរខាងក្ដី អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**២៣-ន ឱគុណ្ឋិតោ អន្តរឃរេ គមិស្សាមីតិ សិក្ខាករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ ។

**ន ឱគុណ្ឋិតេន អន្តរឃរេ គន្តព្វំ ។** ភិក្ខុមិនត្រូវទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះឡើយ ។

**យោ អនាទរិយំ បដិច្ច សសីសំ បារុបិត្វា អន្តរឃរេ គច្ឆតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**២៤-ន ឱគុណ្ឋិតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនទទូរក្បាលអង្គុយក្នុងចន្លោះផ្ទះ។

**ន ឱគុណ្ឋិតេន អន្តរឃរេ និសីទិតព្វំ ។** ភិក្ខុមិនត្រូវទទូរក្បាល អង្គុយនៅក្នុងចន្លោះផ្ទះទេ ។

**យោ អនាទរិយំ បដិច្ច សសីសំ បារុបិត្វា អន្តរឃរេ និសីទតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយទទូរក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**២៥-ន ឧក្កុដិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនចំអើតជើងដើរទៅក្នុងចន្លោះផ្ទះ ។

**ន ឧក្កុដិកាយ អន្តរឃរេ គន្តព្វំ ។** ភិក្ខុមិនត្រូវចំអើតជើងដើរទៅក្នុងចន្លោះផ្ទះទេ ។

**យោ អនាទរិយំ បដិច្ច ឧក្កុដិកាយ អន្តរឃរេ គច្ឆតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយដើរចំអើតជើងទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**២៦-ន បល្លត្ថិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តី សិក្សាថា អាត្មាអញនឹងមិនអង្គុយត្របោមក្បាលជង្គង់ ក្នុងចន្លោះផ្ទះ។

**ន បល្លត្ថិកាយ អន្តរឃរេ និសីទិតព្វំ ។** ភិក្ខុមិនត្រូវអង្គុយត្របោមក្បាលជង្គង់ ក្នុងចន្លោះផ្ទះឡើយ ។

**យោ អនាទរិយំ បដិច្ច ហត្ថបល្លត្ថិកាយ វា ទុស្ស-បល្លត្ថិកាយ វា អន្តរឃរេ និសីទតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ អង្គុយត្របោមក្បាលជង្គង់ ដោយ

ដៃក្តី ត្របោមដោយសំពត់រឹតក្តី ក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**ឆព្វីសតិ សារុប្បា**[៤]

(ចប់) សារុប្បម្ភៃប្រាំមួយ

**២៧-សក្កច្ចំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា** ។ ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងទទួលអាហារបិណ្ឌបាតដោយគោរព។

**សក្កច្ចំ បិណ្ឌបាតោ បដិគ្គហេតព្វោ** ។ ភិក្ខុត្រូវទទួលអាហារបិណ្ឌបាតដោយគោរព ។

**យោ អនាទរិយំ បដិច្ច អសក្កច្ចំ បិណ្ឌបាតំ បដិគ្គណ្ហាតិ ឆឌ្ឌេតុកាមោ វិយ, អាបត្តិ ទុក្កដស្ស** ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយទទួលអាហារបិណ្ឌបាតមិនគោរព ធ្វើដូចជាមានសេចក្តីប្រាថ្នានឹងចាក់ចោល ត្រូវអាបត្តិទុក្កដ ។

**២៨-បត្តសញ្ញី បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា** ។ ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងសម្គាល់តែក្នុងបាត្រទទួលបិណ្ឌបាត ។

**បត្តសញ្ញិនា បិណ្ឌបាតោ បដិគ្គហេតព្វោ** ។ ភិក្ខុត្រូវ

---

[៤] ការពោលជាប់ទាក់ទងនឹងសេចក្តីសមគួរ ។

សម្គាល់ក្នុងបាត្រ ហើយទទួលបិណ្ឌបាត ។

**យោ អនាទរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ បិណ្ឌបាតំ បដិគ្គណ្ហាតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ សម្លឹងមើលទៅក្នុងទីនោះៗ ទទួលបិណ្ឌបាត ត្រូវអាបត្តិទុក្កដ ។

**២៩-សមសូបកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខាករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងទទួលបិណ្ឌបាតឱ្យល្មមគ្នានឹងសម្ល ។

**សមសូបកោ បិណ្ឌបាតោ បដិគ្គហេតព្វោ ។** ភិក្ខុត្រូវទទួលបិណ្ឌបាតល្មមគ្នានឹងសម្ល[៥] ។

**យោ អនាទរិយំ បដិច្ច សូបញ្ញេវ ពហុំ បដិគ្គណ្ហាតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយទទួលយកសម្លច្រើនជាង ត្រូវអាបត្តិទុក្កដ ។

**៣០-សមតិត្តិកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងទទួលបិណ្ឌបាតឱ្យស្មើត្រឹមកណ្តាប់មាត់

---

[៥] អដ្ឋកថា : សម្លដែលមានប្រមាណប៉ុនភាគទី ៤ នៃភត្ត ហៅថា សម្លល្មមនឹងបិណ្ឌបាត ។

បាត្រ ។

**សមតិត្តិកោ បិណ្ឌបាតោ បដិគ្គហេតព្វោ** ។ ភិក្ខុត្រូវទទួលបិណ្ឌបាតឱ្យពេញស្មើត្រឹមកណ្ដាប់មាត់បាត្រ ។

**យោ អនាទរិយំ បដិច្ច ថូបីកតំ បិណ្ឌបាតំ បដិគ្គណ្ហាតិ, អាបត្តិ ទុក្កដស្ស** ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើហើយទទួលបិណ្ឌបាតឱ្យកំពុងលើសកណ្ដាប់មាត់បាត្រទៅត្រូវអាបត្តិទុក្កដ ។

**ខម្ភកវគ្គោ តតិយោ**

ខម្ភកវគ្គទី៣ (ចប់)

**៣១-សក្កច្ចំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ។ ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញ នឹងឆាន់ អាហារបិណ្ឌបាតដោយគោរព ។

**សក្កច្ចំ បិណ្ឌបាតោ ភុញ្ជិតព្វោ** ។ ភិក្ខុត្រូវឆាន់បិណ្ឌបាតដោយគោរព ។

**យោ អនាទរិយំ បដិច្ច អសក្កច្ចំ បិណ្ឌបាតំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស** ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើហើយឆាន់បិណ្ឌបាតមិនគោរព ធ្វើហាក់ដូចជាមិនចង់ឆាន់

ត្រូវ អាបត្តិទុក្កដ ។

**៣២-បត្តសញ្ញី បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ។ ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងសម្គាល់តែក្នុងឆាន់បិណ្ឌបាត ។

**បត្តសញ្ញិនា បិណ្ឌបាតោ ភុញ្ជិតព្វោ** ។ ភិក្ខុត្រូវតែសម្គាល់តែក្នុងបាត្រ ហើយឆាន់បិណ្ឌបាត ។

**យោ អនាទរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ បិណ្ឌបាតំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស** ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ សម្លឹងមើលទៅទីនោះ ៗ ឆាន់បិណ្ឌបាតបណ្ដើរ ត្រូវអាបត្តិទុក្កដ ។

**៣៣-សបទានំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ។ ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹង ឆាន់បិណ្ឌបាតរាចឱ្យស្មើ ។

**សបទានំ បិណ្ឌបាតោ ភុញ្ជិតព្វោ** ។ ភិក្ខុត្រូវឆាន់បិណ្ឌបាតរាចឱ្យស្មើ ។

**យោ អនាទរិយំ បដិច្ច តហំ តហំ ឱមសិត្វា បិណ្ឌបាតំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស** ។ ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ កកាយបាយឱ្យខ្វះក្នុងទីនោះ ៗ ឆាន់បិណ្ឌបាត ត្រូវ

អាបត្តិទុក្កដ ។

**៣៨-សមសូបកំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹង ឆាន់បិណ្ឌបាតឱ្យល្មមគ្នានឹងសម្ល ។

**សមសូបកោ បិណ្ឌបាតោ ភុញ្ជិតព្វោ ។** ភិក្ខុត្រូវឆាន់បិណ្ឌបាតឱ្យល្មមគ្នានឹងសម្ល ។

**យោ អនាទរិយំ បដិច្ច សូបញ្ចេវ ពហុំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ឆាន់សម្លឱ្យច្រើនជាង ត្រូវអាបត្តិទុក្កដ ។

**៣៥-ន ថូបតោ ឱមទ្ទិត្វា បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនច្រមត្រង់កំពូលបាយ ហើយឆាន់បិណ្ឌបាត ។

**ន ថូបកតោ ឱមទ្ទិត្វា បិណ្ឌបាតោ ភុញ្ជិតព្វោ ។** ភិក្ខុមិនត្រូវច្រមត្រង់កំពូលបាយ ហើយឆាន់បិណ្ឌបាតទេ ។

**យោ អនាទរិយំ បដិច្ច ថូបកតោ ឱមទ្ទិត្វា បិណ្ឌបាតំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ

ច្រមត្រង់កំពូលបាយហើយឆាន់បិណ្ឌបាត ត្រូវអាបត្តិទុក្កដ។

**៣៦-ន សូបំ វា ព្យញ្ជនំ វា ឱទនេនបដិច្ឆាទេស្សាមិ ភិយ្យោកម្យតំ ឧបាទាយាតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថាអាត្មាអញ នឹងមិនកកាយបាយលុបសម្ល ឬម្ហូបព្រោះអាស្រ័យសេចក្តីល្មោភច្រើន ។

**ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេតព្វំ ភិយ្យោកម្យតំ ឧបាទាយ ។** ភិក្ខុមិនត្រូវកកាយបាយលុបសម្ល ឬម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើនទេ ។

**យោ អនាទរិយំ បដិច្ច សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេតិ ភិយ្យោកម្យតំ ឧបាទាយ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយកកាយបាយលុបសម្ល ឬម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើន ត្រូវអាបត្តិទុក្កដ ។

**៣៧-ន សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញឥតមាន ជម្ងឺនឹងមិនសូម

សម្ល ឬបាយដើម្បីប្រយោជន៍ខ្លួនឯងហើយឆាន់ ។

**ន សូបំ វា ឱទនំ វា អគិលានេន អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិតព្វំ ។** ភិក្ខុឥតមានជម្ងឺ មិនត្រូវសូមសម្ល ឬបាយ ដើម្បីប្រយោជន៍ខ្លួនហើយឆាន់ទេ ។

**យោ អនាទរិយំ បដិច្ច សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណាឥតមានជម្ងឺអាស្រ័យសេចក្ដីមិនអើពើ សូមសម្ល ឬបាយ ដើម្បីប្រយោជន៍ខ្លួនហើយឆាន់ ត្រូវអាបត្តិទុក្កដ ។

**៣៨-ន ឧជ្ឈានសញ្ញី បរេសំ បត្តំឱលោកេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនប្រុងលើកទោសហើយ សម្លឹងមើលបាត្រពួកភិក្ខុដទៃ ។

**ន ឧជ្ឈានសញ្ញិនា បរេសំ បត្តោ ឱលោកេតព្វោ ។** ភិក្ខុមិនត្រូវសម្លឹងមើលបាត្រពួកភិក្ខុដទៃ ដោយប្រុងនឹងលើកទោសទេ ។

**យោ អនាទរិយំ បដិច្ច ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយប្រុងនឹងលើកទោស ក៏សម្លឹងមើលបាត្រពួកភិក្ខុ

ឯទៀត ត្រូវអាបត្តិទុក្កដ ។

**៣៩-នាតិមហន្តំ កពឡំ ករិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនធ្វើពំនូតបាយឱ្យធំពេក ។

**នាតិមហន្តោ កពឡោ កាតព្វោ ។** ភិក្ខុមិនត្រូវធ្វើពំនូតបាយឱ្យធំពេកទេ ។

**យោ អនាទរិយំ បដិច្ច មហន្តំ កពឡំ ករោតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើពំនូតបាយឱ្យធំពេក ត្រូវអាបត្តិទុក្កដ ។

**៤០-បរិមណ្ឌលំ អាលោបំ ករិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងធ្វើពំនូតបាយឱ្យជាបរិមណ្ឌល គឺឱ្យមូល ។

**បរិមណ្ឌលោ អាលោបោ កាតព្វោ ។** ភិក្ខុត្រូវធ្វើពំនូតបាយឱ្យជាបរិមណ្ឌល ។

**យោ អនាទរិយំ បដិច្ច ទីឃំ អាលោបំ ករោតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើពំនូតបាយឱ្យវែង ត្រូវអាបត្តិទុក្កដ ។

**សក្កច្ចវគ្គោ ចតុត្ថោ** សក្កច្ចវគ្គទី៤ (ចប់)

**៤១-ន អនាហដេ កពឡេ មុខទ្វារំ វិវរិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញកាលពំនូតបាយមិនទាន់មកដល់ នឹងមិនបើកទ្វារមាត់ ។

**ន អនាហដេ កពឡេ មុខទ្វារំ វិវរិតព្វំ ។** ភិក្ខុមិនត្រូវហារមាត់ចាំពំនូតបាយដែលមិនទាន់មកដល់មាត់ទេ ។

**យោ អនាទរិយំ បដិច្ច អនាហដេ កពឡេ មុខទ្វារំ វិវរតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើហើយហារមាត់ចាំពំនូតបាយដែលមិនទាន់មកដល់មាត់ ត្រូវអាបត្តិទុក្កដ ។

**៤២-ន ភុញ្ជមានោ សព្វំ ហត្ថំ មុខេបក្ខិបិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញកាលឆាន់ នឹងមិនញាត់ម្រាមដៃទាំងអស់ចូលទៅក្នុងមាត់ ។

**ន ភុញ្ជមានេន សព្វោ ហត្ថោ មុខេ បក្ខិបិតព្វោ ។** ភិក្ខុកាលឆាន់មិនត្រូវញាត់ (ម្រាម) ដៃទាំងអស់ចូលទៅក្នុងមាត់ទេ ។

**យោ អនាទរិយំ បដិច្ច ភុញ្ជមានោ សព្វំ ហត្ថំ មុខេ បក្ខិបតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆាន់បាយញាត់ (ម្រាម) ដៃទាំងអស់ចូលទៅក្នុងមាត់ ត្រូវអាបត្តិទុក្កដ ។

**៤៣-ន សកពឡេន មុខេន ព្យាហរិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិននិយាយទាំងពំនូតបាយនៅក្នុងមាត់ ។

**ន សកពឡេន មុខេន ព្យាហរិតព្វំ ។** ភិក្ខុមិនត្រូវនិយាយទាំងពំនូតបាយនៅក្នុងមាត់ទេ ។

**យោ អនាទរិយំ បដិច្ច សកពឡេន មុខេន ព្យាហរតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយនិយាយទាំងពំនូតបាយ នៅក្នុងមាត់ ត្រូវអាបត្តិទុក្កដ ។

**៤៤-ន បិណ្ឌុក្ខេបកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់បោះដុំបាយទៅក្នុងមាត់ ។

**ន បិណ្ឌុក្ខេបកំ ភុញ្ជិតព្វំ ។** ភិក្ខុមិនត្រូវឆាន់បោះដុំបាយ (ទៅក្នុងមាត់) ទេ ។

**យោ អនាទរិយំ បដិច្ច បិណ្ឌុក្ខេបកំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់បោះដុំបាយ (ទៅក្នុងមាត់) ត្រូវអាបត្តិទុក្កដ ។

**៤៥-ន កពឡាវច្ឆេទកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់កាត់ពំនូតបាយ ។

**ន កពឡាវច្ឆេទកំ ភុញ្ជិតព្វំ ។** ភិក្ខុមិនត្រូវឆាន់កាត់ពំនូតបាយទេ ។

**យោ អនាទរិយំ បដិច្ច កពឡាវច្ឆេទកំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់កាត់ពំនូតបាយ ត្រូវអាបត្តិទុក្កដ ។

**៤៦-ន អវគណ្ឌការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់បៀមពំនូតបាយក្នុងថ្ពាល់ ។

**ន អវគណ្ឌការកំ ភុញ្ជិតព្វំ ។** ភិក្ខុមិនត្រូវឆាន់បៀមពំនូតបាយក្នុងថ្ពាល់ទេ ។

**យោ អនាទរិយំ បដិច្ច ឯកតោ វា ឧភតោ វា គណ្ឌំ**

**កត្វា ភុញ្ជតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់បៀមពំនូតបាយ ក្នុងថ្ពាល់ម្ខាង ឬទាំងពីរខាង ត្រូវអាបត្តិទុក្កដ ។

**៤៧-ន ហត្ថនិទ្ធូនកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់រលាស់ដៃ ។

**ន ហត្ថនិទ្ធូនកំ ភុញ្ជិតព្វំ ។** ភិក្ខុមិនត្រូវឆាន់រលាស់ដៃទេ ។

**យោ អនាទរិយំ បដិច្ច ហត្ថនិទ្ធូនកំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់រលាស់ដៃបណ្ដើរ ត្រូវអាបត្តិទុក្កដ ។

**៤៨-ន សិត្ថាវការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់ធ្វើគ្រប់បាយឱ្យជ្រុះរោយរាយ ។

**ន សិត្ថាវការកំ ភុញ្ជិតព្វំ ។** ភិក្ខុមិនត្រូវឆាន់ធ្វើគ្រាប់បាយ ឱ្យជ្រុះរោយរាយទេ ។

**យោ អនាទរិយំ បដិច្ច សិត្ថាវការកំ ភុញ្ជតិ, អាបត្តិ**

ទុក្កដស្ស ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់ធ្វើគ្រាប់បាយ ឱ្យជ្រុះរោយរាយ ត្រូវអាបត្តិទុក្កដ ។

**៤៩-ន ជិវ្ហានិច្ឆារកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់លិទ្ធបបូរមាត់ ។

**ន ជិវ្ហានិច្ឆារកំ ភុញ្ជិតព្វំ ។** ភិក្ខុមិនត្រូវឆាន់លៀនអណ្ដាតទេ ។

**យោ អនាទរិយំ បដិច្ច ជិវ្ហានិច្ឆារកំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់លៀនអណ្ដាត ត្រូវអាបត្តិទុក្កដ ។

**៥០-ន ចបុចបុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់ធ្វើឱ្យឮផ្លប់ៗ ។

**ន ចបុចបុការកំ ភុញ្ជិតព្វំ ។** ភិក្ខុមិនត្រូវឆាន់ធ្វើសំឡេងឱ្យឮផ្លប់ៗ ទេ ។

**យោ អនាទរិយំ បដិច្ច ចបុចបុការកំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់ធ្វើសំឡេងឱ្យឮផ្លប់ៗ ត្រូវអាបត្តិទុក្កដ ។

**កពឡវគ្គោ បញ្ចមោ**

កពឡវគ្គទី៥ ( ចប់ )

**៥១-ន សុរុសុរុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់ធ្វើឱ្យឮគ្រូកៗ ។

**ន សុរុសុរុការកំ ភុញ្ជិតព្វំ** ។ភិក្ខុមិនត្រូវឆាន់ធ្វើសំឡេងឱ្យឮគ្រូក ៗ ទេ ។

**យោ អនាទរិយំ បដិច្ច សុរុសុរុការកំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស** ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់ធ្វើសំឡេងឱ្យឮគ្រូក ៗ ត្រូវអាបត្តិទុក្កដ ។

**៥២-ន ហត្ថនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា** ។ ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់លិទ្ធដៃ ។

**ន ហត្ថនិល្លេហកំ ភុញ្ជិតព្វំ** ។ ភិក្ខុមិនត្រូវឆាន់លិទ្ធដៃទេ ។

**យោ អនាទរិយំ បដិច្ច ហត្ថនិល្លេហកំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស** ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយឆាន់លិទ្ធដៃ ត្រូវអាបត្តិទុក្កដ ។

**៥៣-ន បត្តនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់កោសបាត្រ ។

**ន បត្តនិល្លេហកំ ភុញ្ជិតព្វំ ។** ភិក្ខុមិនត្រូវឆាន់ កោស[៦] បាត្រទេ ។

**យោ អនាទរិយំ បដិច្ច បត្តនិល្លេហកំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆាន់កោសបាត្រ ត្រូវអាបត្តិទុក្កដ ។

**៥៤-ន ឱដ្ឋនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់លិទ្ធបបូរមាត់ ។

**ន ឱដ្ឋនិល្លេហកំ ភុញ្ជិតព្វំ ។** ភិក្ខុមិនត្រូវឆាន់លិទ្ធបបូរមាត់ទេ ។

**យោ អនាទរិយំ បដិច្ច ឱដ្ឋនិល្លេហកំ ភុញ្ជតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆាន់លិទ្ធបបូរមាត់ ត្រូវអាបត្តិទុក្កដ ។

---

[៦] ក្នុងបិដកថា " លិទ្ធបាត្រ " ។

**៥៥-ន សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញមានដៃប្រឡាក់ដោយអាមិស នឹងមិនទទួលភាជនៈ ទឹកសម្រាប់ឆាន់ ។

**ន សាមិសេន ហត្ថេន បានីយថាលកោ បដិគ្គហេតព្វោ ។** ភិក្ខុមានដៃប្រឡាក់ដោយអាមិសៈ មិនត្រូវទទួលភាជនៈទឹកសម្រាប់ឆាន់ទេ ។

**យោ អនាទរិយំ បដិច្ច សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គណ្ហាតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ មានដៃប្រឡាក់ដោយអាមិសៈ ទទួលភាជនៈទឹកសម្រាប់ឆាន់ ត្រូវអាបត្តិទុក្កដ ។

**៥៦-ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនចាក់ទឹកលាងបាត្រទាំងគ្រប់បាយក្នុងចន្លោះផ្ទះ ។

**ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេតព្វំ ។** ភិក្ខុមិនត្រូវចាក់ទឹកលាងបាត្រទាំងគ្រាប់បាយទៅក្នុងចន្លោះផ្ទះទេ។

**យោ អនាទរិយំ បដិច្ច សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ចាក់ទឹកលាងបាត្រទាំងគ្រាប់បាយទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

**សមត្ថិស ភោជនប្បដិសំយុត្តា**[៧]

(ចប់) ភោជនប្បដិសំយុត្ត ៣០ គត់ ។

**៥៧-ន ឆត្តបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសម្ដែងធម៌ ដល់មនុស្សគ្មានជំងឺ មានឆត្រក្នុងដៃ ។

**ន ឆត្តបាណិស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។** ភិក្ខុមិនត្រូវសម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានឆត្រនៅក្នុងដៃទេ ។

**យោ អនាទរិយំ បដិច្ច ឆត្តបាណិស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានឆត្រក្នុងដៃ ត្រូវអាបត្តិទុក្កដ ។

---

[៧] ការពោលទាក់ទងនឹងភោជន (អាហារ)

**៥៨-ន ទណ្ឌបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ ដល់មនុស្សគ្មានជំងឺ មានដំបង ក្នុងដៃ ។

**ន ទណ្ឌបាណិស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។** ភិក្ខុ មិនត្រូវសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺមានដំបងនៅក្នុងដៃទេ ។

**យោ អនាទរិយំ បដិច្ច ទណ្ឌបាណិស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្សគ្មានជម្ងឺមានដំបង នៅក្នុងដៃ ត្រូវអាបត្តិទុក្កដ ។

**៥៩-ន សត្ថបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ ដល់មនុស្សគ្មានជំងឺ មានគ្រឿងសស្ត្រាក្នុងដៃ ។

**ន សត្ថបាណិស្ស អគិលានស្ស ធម្មោ ទេសេតព្វោ។** ភិក្ខុ មិនត្រូវសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺមានគ្រឿងសស្ត្រា

នៅក្នុងដៃទេ ។

**យោ អនាទរិយំ បដិច្ច សត្ថបាណិស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធមិដល់មនុស្សគ្មានជម្ងឺមានគ្រឿងសស្ត្រានៅក្នុងដៃ ត្រូវអាបត្តិទុក្កដ ។

**៦០-ន អាវុធបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសម្ដែងធមិ ដល់មនុស្សគ្មានជំងឺ មានគ្រឿងអាវុធក្នុងដៃ ។

**ន អាវុធបាណិស្ស អគិលានស្ស ធម្មោ ទេសេតព្វោ។** ភិក្ខុ មិនត្រូវសម្ដែងធមិដល់មនុស្សគ្មានជម្ងឺមានគ្រឿងអាវុធនៅក្នុងដៃទេ ។

**យោ អនាទរិយំ បដិច្ច អាវុធបាណិស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយសម្ដែងធមិដល់មនុស្សគ្មានជម្ងឺមានគ្រឿងអាវុធនៅក្នុងដៃ ត្រូវអាបត្តិទុក្កដ ។

**សុរុសុរុវគ្គោ ឆដ្ឋោ** សុរុសុរុវគ្គទី ៦ (ចប់)

**៦១-ន ពាទុការូឡ្ហស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ពាក់ទ្រនាប់ជើង ។

**ន ពាទុការុឡ្ហស្សអគិលានស្សធម្មោ ទេសេតព្វោ ។**ភិក្ខុមិនត្រូវសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ ពាក់ទ្រនាប់ជើងទេ ។

**យោ អនាទរិយំ បដិច្ច អក្កន្តស្ស វា បដិមុក្កស្ស វា ឱមុក្កស្ស វា អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុ ណាអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ ជាន់ទ្រនាប់ជើងក្តី ពាក់ក្តី ដោះបង្ហើបកែងបន្តិចក្តី ត្រូវអាបត្តិទុក្កដ ។

**៦២-ន ឧបាហនារូឡ្ហស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ ដល់មនុស្សគ្មានជំងឺ ពាក់ស្បែកជើង ។

**ន ឧបាហនារុឡ្ហស្សអគិលានស្សធម្មោ ទេសេតព្វោ។** ភិក្ខុ មិនត្រូវសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ ពាក់ស្បែកជើងទេ ។

**យោ អនាទរិយំ បដិច្ច អក្កន្តស្ស វា បដិមុក្កស្ស វា ឱមុក្កស្ស វា អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស ។**
ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺ ជាន់លើស្បែកជើងក្ដី ពាក់ក្ដី ដោះបង្ហើបកែងបន្ទិចក្ដី ត្រូវអាបត្តិទុក្កដ ។

**៦៣-ន យានគតស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសម្ដែងធម៌ ដល់មនុស្សគ្មានជំងឺ នៅលើយាន ។

**ន យានគតស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។**
ភិក្ខុ មិនត្រូវសម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺ នៅលើយានទេ ។

**យោ អនាទរិយំ បដិច្ច យានគតស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុ ណាអាស្រ័យសេចក្ដីមិនអើពើ ហើយសម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺ នៅលើយាន ត្រូវអាបត្តិទុក្កដ ។

**៦៤-ន សយនគតស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា

អាត្មាអញនឹងមិនសម្តែងធម៌ ដល់មនុស្សគ្មានជំងឺ នៅលើដំណេក ។

**ន សយនគតស្ស អគិលានស្ស ធម្មោ ទេសេតព្វោ។** ភិក្ខុ មិនត្រូវសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ នៅលើដំណេក ទេ ។

**យោ អនាទរិយំ បដិច្ច អន្តមសោ ឆមាយម្បិ និបន្នស្ស សយនគតស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ ដោយហោចទៅសូម្បីដេកនៅលើផែនដី ក៏ត្រូវអាបត្តិទុក្កដ ។

**៦៥-ន បល្លត្ថិកាយ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ ដល់មនុស្សគ្មានជំងឺ អង្គុយត្របោមក្បាលជង្គង់ ។

**ន បល្លត្ថិកាយ និសិន្នស្ស អគិលានស្ស ធម្មោ ទេសេ-តព្វោ ។** ភិក្ខុមិនត្រូវសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយត្របោមក្បាលជង្គង់ទេ ។

**យោ អនាទរិយំ បដិច្ច ហត្ថបល្លត្ថិកាយ វា ទុស្សបល្លត្ថិកាយ វា និសិន្នស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយត្របោមក្បាលជង្គង់ដោយដៃក្តី អង្គុយត្របោមក្បាលជង្គង់ដោយសំពត់ក្តី ត្រូវអាបត្តិទុក្កដ ។

**៦៦-ន វេដ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ ដល់មនុស្សគ្មានជំងឺជួតក្បាល ។

**ន វេឋិតសីសស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។** ភិក្ខុមិនត្រូវសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ ជួតក្បាលទេ ។

**យោ អនាទរិយំ បដិច្ច វេឋិតសីសស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្សគ្មានជម្ងឺជួតក្បាល ត្រូវអាបត្តិទុក្កដ ។

**៦៧-ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មំ**

**ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ទទូរក្បាល ។

**ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មោ ទេសេតព្វោ។** ភិក្ខុមិនត្រូវសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ ទទូរក្បាលទេ ។

**យោ អនាទរិយំ បដិច្ច ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្សគ្មានជម្ងឺទទូរក្បាល ត្រូវអាបត្តិទុក្កដ ។

**៦៨-ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនអង្គុយផ្ទាល់លើផែនដី ហើយសម្តែងធម៌ដល់មនុស្សគ្មានជំងឺអង្គុយលើអាសនៈ ។

**ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។**ភិក្ខុមិនត្រូវអង្គុយផ្ទាល់លើផែនដី ហើយ

សម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយនៅលើអាសនៈទេ ។

**យោ អនាទរិយំ បដិច្ច ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ អង្គុយនៅលើផែនដី ហើយសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយនៅលើអាសនៈ ត្រូវអាបត្តិទុក្កដ ។

**៦៩-ន នីចេ អាសនេ និសីទិត្វា ឧច្ចេអាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនអង្គុយលើអាសនៈទាបហើយសម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈខ្ពស់ ។

**ន នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។** ភិក្ខុមិនគប្បីអង្គុយលើអាសនៈទាប ហើយសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយលើអាសនៈខ្ពស់ទេ ។

**យោ អនាទរិយំ បដិច្ច នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ**

**ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ អង្គុយលើអាសនៈទាប ហើយសម្ដែងធមិដល់មនុស្សគ្មានជម្ងឺអង្គុយលើអាសនៈខ្ពស់ ត្រូវអាបត្តិទុក្កដ ។

**៧០-ន ឋិតោ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឈរសម្ដែងធមិដល់មនុស្សគ្មានជំងឺ ដែលអង្គុយ ។

**ន ឋិតេន និសិន្នស្ស អគិលានស្ស ធម្មោ ទេសេតព្វោ។** ភិក្ខុមិនត្រូវឈរសម្ដែងធមិ ដល់មនុស្សគ្មានជម្ងឺអង្គុយទេ ។

**យោ អនាទរិយំ បដិច្ច ឋិតោ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស ។**ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយឈរសម្ដែងធមិដល់មនុស្សគ្មានជម្ងឺ អង្គុយនៅ ត្រូវអាបត្តិទុក្កដ ។

**៧១-ន បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាអាត្មាអញនឹងមិនដើរខាងក្រោយហើយ សម្ដែងធមិដល់មនុស្សគ្មានជម្ងឺដើរខាងមុខ ។

**ន បច្ឆតោ គច្ឆន្តេន បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។** ភិក្ខុមិនត្រូវដើរខាងក្រោយ សម្តែងធមិដល់មនុស្សគ្មានជម្ងឺដើរខាងមុខទេ ។

**យោ អនាទរិយំ បដិច្ច បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស ។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ដើរខាងក្រោយ ហើយសម្តែងធមិដល់មនុស្សគ្មានជម្ងឺដើរខាងមុខ ត្រូវអាបត្តិទុក្កដ ។

**៧២-ន ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនដើរក្រៅផ្លូវហើយសម្តែងធមិ ដល់មនុស្សគ្មានជំងឺ ដើរតាមផ្លូវ ។

**ន ឧប្បថេន គច្ឆន្តេន បថេន គច្ឆន្តស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។** ភិក្ខុមិនត្រូវដើរក្រៅផ្លូវ សម្តែងធមិដល់មនុស្សគ្មានជម្ងឺដើរតាមផ្លូវទេ ។

**យោ អនាទរិយំ បដិច្ច ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសេតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយដើរក្រៅផ្លូវសម្តែងធមិដល់ មនុស្សគ្មានជម្ងឺ ដើរតាមផ្លូវ ត្រូវអាបត្តិទុក្កដ ។

## សោឡស ធម្មទេសនាបដិសំយុត្តា[៨]

## (ចប់) ធម្មទេសនាបដិសំយុត្ត ១៦

**៧៣-ន ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញគ្មានជំងឺនឹងមិនឈរបន្ទោរបង់ឧច្ចារៈ ឬបស្សាវៈ ។

**ន ឋិតេន អគិលានេន ឧច្ចារោ វា បស្សាវោ វា កាតព្វោ។** ភិក្ខុគ្មានជម្ងឺ មិនត្រូវឈរបន្ទោរបង់ឧច្ចារៈ ឬបស្សាវៈទេ ។

**យោ អនាទរិយំ បដិច្ច ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករោតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ គ្មានជម្ងឺហើយឈរបន្ទោរបង់ឧច្ចារៈ ឬបស្សាវៈ ត្រូវអាបត្តិទុក្កដ ។

**៧៤-ន ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញគ្មានជំងឺនឹងមិនបន្ទោរបង់ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្តោះទឹកមាត់លើ

---

[៨] ការពោលជាប់ទាក់ទងនឹងការសម្តែងធមិ

ស្មៅស្រស់ ឬឈើស្រស់ ។

**ន ហរិតេ អគិលានេន ឧច្ចារោ វា បស្សាវោ វា ខេឡោ វា កាតព្វោ។** ភិក្ខុគ្មានជម្ងឺមិនត្រូវបន្ទោរបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់លើស្មៅស្រស់ ឬឈើស្រស់ទេ ។

**យោ អនាទរិយំ បដិច្ច ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណាគ្មានជម្ងឺអាស្រ័យសេចក្តីមិនអើពើ ហើយបន្ទោរបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់លើស្មៅស្រស់ ឬឈើស្រស់ ត្រូវអាបត្តិទុក្កដ ។

**៧៥-ន ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ (សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញគ្មានជំងឺនឹងមិនបន្ទោរបង់ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្តោះទឹកមាត់លើទឹក ។

**ន ឧទកេ អគិលានេន ឧច្ចារោ វា បស្សាវោ វា ខេឡោ វា កាតព្វោ។** ភិក្ខុគ្មានជម្ងឺមិនត្រូវបន្ទោរបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ ដាក់លើទឹកទេ ។

**យោ អនាទរិយំ បដិច្ច ឧទកេ អគិលានោ ឧច្ចារំ វា**

**បស្សាវំ វា ខេឡំ វា ករោតិ, អាបត្តិ ទុក្កដស្ស។** ភិក្ខុណា គ្មានជម្ងឺអាស្រ័យសេចក្តីមិនអើពើ ហើយបន្ទោរបង់ឧច្ចារៈ ឬ បស្សាវៈ ឬស្តោះទឹកមាត់ ដាក់លើទឹក ត្រូវអាបត្តិទុក្កដ ។

**តយោ បកិណ្ណកា និដ្ឋិតា**

ចប់ បកិណ្ណក ៣

**បាទុកាវគ្គោ សត្តមោ**

បាទុកាវគ្គទី ៧ (ចប់)

**ឧទ្ទិដ្ឋា ខោ អាយស្មន្តោ (បញ្ចសត្តតិ) សេខិយាធម្មា ។**

**តត្ថាយស្មន្តេ  បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ?**

**ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ?**

**តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា?**

**បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី ។**

**ឯវមេតំ ធារយាមិ ។**

បពិត្រលោកអ្នកមានអាយុទាំងឡាយ, វត្តដែលគប្បីសិក្សាទាំង (ចិតសិបប្រាំ), គឺខ្ញុំព្រះករុណាបានសម្តែងរួចហើយ ។

ខ្ញុំព្រះករុណាសូមសួរលោកអ្នកមានអាយុទាំងឡាយ, ក្នុងសេខិយវត្តទាំងនោះ,

លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ?

ខ្ញុំព្រះករុណាសូមសួរជាគម្រប់ពីរដងទៀត,

លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ?

ខ្ញុំព្រះករុណាសូមសួរជាគម្រប់បីដងទៀត,

លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ?

លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធ ក្នុងសេខិយវត្តទាំងនុ៎ះហើយ, ព្រោះហេតុនោះបានជានៅស្ងៀម ។ ខ្ញុំព្រះករុណាសូមចាំទុកនូវហេតុនេះដោយ កិរិយានៅស្ងៀមយ៉ាងនេះ ។

## **សេខិយា និដ្ឋិតា**

ចប់សេខិយវត្ត